01112574

E305/17

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 06 / 2015
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យ៉ា សុខន**
ចៅក្រម Claudia FENZ
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារទាំងឡាយដែលបានស្នើដាក់ នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណើមួយចំនួនរបស់ភាគីសុំឱ្យទទួលយក និង ដាក់ចូលទៅក្នុងសំណុំរឿង ០០២/០២ នូវឯកសារនានាដែលមាននៅក្នុងបញ្ជីឯកសារដែលបានដាក់ អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ សេចក្តីសម្រេចនេះបង្ហាញពីការពិចារណារបស់អង្គជំនុំជម្រះទៅលើឯកសារទាំងនេះ និង ដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារនានាដែលមាននៅក្នុងតារាងភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចនេះ[1]។

## ២. ប្រវត្តិនីតិវិធី

២. ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំណុំរឿងទាំងអស់ដែលជាលទ្ធផលនៃការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ គឺជាផ្នែកមួយនៃសំណុំរឿង ០០២ ដដែល[2]។ ភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ត្រូវបានវាយតម្លៃរួចហើយ អនុលោមទៅតាមលក្ខខណ្ឌនានានៃវិធាន ៨៧ នៃវិធានផ្ទៃក្នុង[3]។ ហេតុនេះ ពុំចាំបាច់វាយតម្លៃសាជាថ្មីពីភាពអាចទទួលយកបាននៃឯកសារដែលត្រូវបានទទួលយក នៅដំណាក់កាលដំបូងទេ។

---

[1] នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ នៅក្នុងការត្រៀមសម្រាប់សវនាការស្តាប់ការបង្ហាញឯកសារគន្លឹះដែលនឹងធ្វើឡើងនៅថ្ងៃទី ២៧, ២៨ និង ៣០ ខែ មេសា ឆ្នាំ ២០១៥ នោះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទៅឱ្យភាគីជាលក្ខណៈក្រៅផ្លូវការនូវឧបសម្ព័ន្ធទាំងអស់ដែលភ្ជាប់ទៅនឹងសេចក្តីសម្រេចនេះ ដោយបានវាយឈ្មោះឯកសារទាំងអស់ ដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និង ដែលត្រូវបានបដិសេធដោយសេចក្តីសម្រេចនេះ។ អង្គជំនុំជម្រះសាលាដំបូងក៏បានផ្តល់ឱ្យនូវសំណៅថតចម្លងនៃឧបសម្ព័ន្ធទាំងនេះនៅថ្ងៃទី ២៤ ខែ ខែ មេសា ឆ្នាំ ២០១៥។ ឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះត្រូវបានកែប្រែបន្ថែមទៀត ដើម្បីបញ្ចូលឯកសារចំនួន ១៦ (ឯកសារ D108/28.329 ឯកសារ D108/28.352 ឯកសារ D125/180 ឯកសារ D359/1/1.1.28 ឯកសារ D359/1/1.1.53 ឯកសារ E189/3/1/7.1.1 ឯកសារ E189/3/1/7.1.2 ឯកសារ E189/3/1/7.1.3 ឯកសារ E189/3/1/7.1.4 ឯកសារ E282.1.14 ឯកសារ E282.1.15 ឯកសារ E282.1.16 ឯកសារ E305/12.32 ឯកសារ E305/12.38R ឯកសារ E307/5.2.8 និងឯកសារ E307/5.2.9) ទាក់ទិននឹងសេចក្តីសម្រេចនានាដែលបានចេញដោយអង្គជំនុំជម្រះ បន្ទាប់ពីសំណៅថតចម្លងនៃឧបសម្ព័ន្ធត្រូវបានចែកជូន។

[2] ការបញ្ជាក់ទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E302/5 ("ការបញ្ជាក់បំភ្លឺទាក់ទិននឹងភស្តុតាង និង នីតិវិធី") ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

[3] ការបញ្ជាក់បំភ្លឺទាក់ទិននឹងភស្តុតាង និង នីតិវិធី កថាខណ្ឌ ៧។

៣. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ភាគីទាំងអស់ឱ្យផ្តល់បញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាព និង បានដាក់កាលពីពេលមុន ព្រមទាំងបញ្ជីវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព ដែលខ្លួនមានបំណងដាក់ចូលក្នុងសំណុំរឿង ០០២/០២[4]។ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ភាគីបានដាក់បញ្ជីឯកសាររបស់ខ្លួនដែលបានធ្វើបច្ចុប្បន្នភាព[5]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បញ្ជីឯកសារបន្ថែមនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤[6]។ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារបន្ថែមកាលពីខែ កញ្ញា ឆ្នាំ ២០១៤[7]។ ពុំមានភាគីណាស្នើសុំដាក់បញ្ចូលវត្ថុតាងណាមួយទៅក្នុងសំណុំរឿង ០០២/០២ ឡើយ[8]។

៤. សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់សំណើរួមសុំឱ្យបំភ្លឺថាតើ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលតម្រូវឱ្យមានការអនុវត្តដោយមានសំអាងហេតុ

---

[4] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាពដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ ឯកសារ E305 ("ដីកាបង្គាប់ឱ្យដាក់សម្ភារៈ") ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ១១, ១២។

[5] ឯកសារស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ("បញ្ជីឯកសាររបស់ ខៀវ សំផន") ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ បញ្ជីឯកសារសវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ឯកសារ E305/13 ("បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា") ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ បញ្ជីឯកសារ និង វត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់ V ឯកសារ E305/14 ("បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី") ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤។ បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង ០០២/០២ ឯកសារ E307/5 ("បញ្ជីឯកសាររបស់ នួន ជា") ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។ ភាគីនីមួយៗបានដាក់បញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ខ្លួន រួមជាមួយនឹងឯកសារជាច្រើនដែលពួកគាត់ដាក់ជូន ជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងការដាក់ឯកសារទាំងនេះ។ នៅក្នុងសេចក្តីសម្រេចនេះ ការយោងទៅលើការដាក់ឯកសាររបស់ភាគីមួយ រួមបញ្ចូលនូវបញ្ជីវត្ថុតាង និង ឯកសារដែលបានធ្វើបច្ចុប្បន្នភាព ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងការដាក់ឯកសារតែមួយនេះ ប្រសិនបើមាន។

[6] សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំឱ្យទទួលយកជាភស្តុតាងនូវសេចក្តីកម្មផ្ទាល់មាត់ និង ឯកសារ ព្រមទាំងវត្ថុតាងនានា ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្នើឱ្យផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ E307/6 ("បញ្ជីឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី") ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

[7] បញ្ជីឯកសារបន្ថែមសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ឯកសារ E305/13/1 ("បញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា") ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៤។

[8] ទោះបីជាសហមេធាវីនាំមុខបានកំណត់សម្ភារៈមួយចំនួនក្នុងចំណោមសម្ភារៈដែលបានស្នើឡើងនៅក្នុងបញ្ជីឯកសាររបស់ខ្លួនថាជាវត្ថុតាងក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាវាជាការសមស្របជាងក្នុងការកំណត់សម្ភារៈទាំងនេះថា ជាឯកសារ។

សម្រាប់វត្ថុតាង ឬ ឯកសារថ្មីនីមួយៗដែលបានដាក់ជូននោះ នឹងយកមកអនុវត្តចំពោះបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាព និង បានដាក់ អនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈដែរ ឬ ទេ[9]។ អង្គជំនុំជម្រះបានសម្រេចថា យោងទៅលើករណីពិសេស អង្គជំនុំជម្រះនឹងចាត់ទុកបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ភាគីថា ជាសំណៅបញ្ជីឯកសារសំណុំរឿង ០០២/០១ ដែលបានកែសម្រួល និង បានដាក់ អនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈ[10]។ ជាលទ្ធផល បញ្ជីឯកសារទាំងនោះពុំចាំបាច់គោរពតាមលក្ខខណ្ឌក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ ហើយពុំចាំបាច់តម្រូវឱ្យមានសារណាដែលមានសំអាងហេតុសម្រាប់ឯកសារនីមួយៗដែលបានស្នើឡើងនោះដែរ[11]។ ទោះបីជាយ៉ាងណាក៏ដោយ ឯកសារទាំងនេះ នៅតែតម្រូវឱ្យបំពេញទៅតាមបទដ្ឋាននៃភាពអាចទទួលយកបាន តាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងដដែល[12]។

៥. នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានផ្តល់ឱកាសឱ្យភាគីដាក់សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សរចំពោះឯកសារផ្សេងៗ ដែលមាននៅក្នុងបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ភាគីដទៃទៀត និង ជំទាស់ទៅនឹងការសន្មតអំពីភាពពាក់ព័ន្ធ និង ភាពជឿទុកចិត្តបានដែលបានផ្តល់ទៅឱ្យឯកសារទាំងឡាយដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ[13]។ ក្នុងពេលទន្ទឹមគ្នានោះដែរ អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីបញ្ជាក់អំពីបំណងរបស់ខ្លួនក្នុងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬ ប្រតិចារឹកនៅក្នុងបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ខ្លួន ដើម្បីធ្វើជាភស្តុតាងសម្រាប់បញ្ជាក់អំពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ[14]។

---

[9] សំណើរួមសុំការសម្រេចឡើងវិញស្តីពីការអនុវត្តវិធាន ៨៧(៤) ក្នុងសំណុំរឿង ០០២/០២ និង សេចក្តីសន្និដ្ឋានទាក់ទងនឹងភាពមិនអាចអនុវត្តបាននៃវិធាន ៨៧(៤) ចំពោះសម្ភារៈដែលមាននៅក្នុងសំណុំរឿងរួចហើយ ឯកសារ E307/1/1 ("សំណើរួម") ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤។

[10] សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេចសាជាថ្មីឡើងវិញលើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ("សេចក្តីសម្រេចលើសំណើរួម") ឯកសារ E307/1/2 ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

[11] សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ១១, ១២។

[12] សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ១១, ១២។

[13] ការកំណត់កាលបរិច្ឆេទសម្រាប់ការជំទាស់ទៅនឹងឯកសារផ្សេងៗ ទាក់ទងនឹងសំណុំរឿង ០០២/០២ ឯកសារ E327 ("ដីកាបង្គាប់ស្តីអំពីការជំទាស់") ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៤ ដល់ ៦។

[14] ដីកាបង្គាប់ស្តីអំពីការជំទាស់ កថាខណ្ឌ ៣។

៦. នៅពេលនេះ អង្គជំនុំជម្រះសម្រេចទៅលើភាពអាចទទួលយកបាននៃឯកសារនានាដែលមាននៅក្នុងបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាព ការជំទាស់របស់ភាគីទៅនឹងឯកសារទាំងនោះ និង ទៅលើសារណាផ្សេងៗទៀតរបស់ភាគី[15]។

## ៣. សារណារបស់ភាគី

### ៣.១ សារណារបស់សហព្រះរាជអាជ្ញា

៧. សហព្រះរាជអាជ្ញាស្នើសុំដាក់ឯកសារសរុបចំនួន ៧.៤៤៧ ឯកសារ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងនោះឯកសារមួយចំនួនត្រូវបានទទួលយកជាភស្តុតាងរួចហើយកាលពីពេលមុននៅក្នុងសំណុំរឿង ០០២/០១[16]។ ពួកគាត់ក៏បានដាក់បញ្ជីឯកសារបន្ថែមដែលរួមមានឯកសារចំនួន ១៤៣ ដោយឯកសារភាគច្រើនគឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើឡើងដោយភាគីដទៃទៀតនៅក្នុងសំណុំរឿង ០០២/០២ ដែលជាលទ្ធផលនៃការត្រៀមរៀបចំសវនាការរបស់ខ្លួន និង ជាការឆ្លើយតបទៅនឹងបញ្ជីឈ្មោះសាក្សីរបស់ភាគីដទៃទៀត[17]។

៨. យោងតាមសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០១ នូវឯកសារចំនួន ១៦ ក្នុងចំណោមឯកសារចំនួន ១៤៣ នៅក្នុងបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា[18]។ ឯកសារចំនួន ១០១ ក្នុងចំណោមឯកសារទាំងនេះស្ថិតក្នុងសំណុំរឿងនាពេលបច្ចុប្បន្ននេះ ប៉ុន្តែមិនទាន់ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅឡើយ[19]។ សហព្រះរាជអាជ្ញាលើកឡើងថា ឯកសារដែលនៅសល់ចំនួន ២៦ គឺទើបតែទទួលបានថ្មីៗ ឬ ទើបតែបោះពុម្ពផ្សាយនាពេលថ្មីៗនេះ[20]។

---

[15] ដីកាបង្គាប់ស្តីអំពីការជំទាស់ កថាខណ្ឌ ៦។

[16] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣, ៥។

[17] បញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១។

[18] បញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២។

[19] បញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[20] បញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។

៩. បញ្ជីឯកសារទាំងពីររបស់សហព្រះរាជអាជ្ញា រួមមានចម្លើយ និង កំណត់ហេតុស្តាប់ចម្លើយ ដែលសហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់ជាភ័ស្តុតាងបញ្ជាក់អំពីអំពើ និង អាប្បកិរិយារបស់ជនជាប់ចោទ[21]។ សហព្រះរាជអាជ្ញាអះអាងថា ឯកសារនីមួយៗក្នុងចំណោមឯកសារទាំងនេះគឺអាចទទួលយកបាន ដោយផ្អែកទៅលើនត្ថិភាពនៃឱកាសក្នុងការសួរដេញដោលសាក្សី[22]។ សហព្រះរាជអាជ្ញាមានបំណងស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយបន្ថែមចំពោះមុខអង្គជំនុំជម្រះប្រសិននត្ថិភាពនៃឱកាសក្នុងការសួរដេញដោល កើតមានឡើងនៅពេលក្រោយមកទៀតនោះ[23]។

១០. សហព្រះរាជអាជ្ញាអះអាងថា ឯកសារមួយចំនួនក្នុងចំណោមឯកសារនៅក្នុងបញ្ជីរបស់ខ្លួនដែលមេធាវីការពារក្តី ខៀវ សំផន បានជំទាស់ថាជាឯកសារច្រំដែល ឬ ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ នោះ គឺមានភាពជាប់ពាក់ព័ន្ធ និង មានតម្លៃជាភ័ស្តុតាងដើម្បីបញ្ជាក់បញ្ហានានាដែលកំពុងតែជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២[24]។

## ៣.២ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

១១. បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួន ១.៣៣៦ ឯកសារ ដែលក្នុងនោះ ឯកសារមួយចំនួនត្រូវបានទទួលយកជាភ័ស្តុតាងរួចហើយនៅក្នុងសំណុំរឿង ០០២/០១[25]។ បញ្ជីឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានឯកសារបន្ថែមចំនួន ១៩[26]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវភ័ស្តុតាងដែល

---

[21] ការដាក់ជូនរបស់សហព្រះរាជអាជ្ញានូវកំណត់ហេតុ និង ប្រតិចារឹកក្នុងគោលបំណងប្រើប្រាស់ជាភ័ស្តុតាងសម្រាប់បញ្ជាក់អំពើ និង អាកប្បកិរិយា ឯកសារ E327/2 ("ការដាក់ជូនរបស់សហព្រះរាជអាជ្ញាសម្រាប់បញ្ជាក់អំពើ និង អាកប្បកិរិយា") ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ២។ ឧបសម្ព័ន្ធ ក – កំណត់ហេតុ និង ប្រតិចារឹកដែលបានដាក់ជូនសម្រាប់បញ្ជាក់អំពើ និង អាកប្បកិរិយា ឯកសារ E327/2.2 ("ឧបសម្ព័ន្ធទៅនឹងការដាក់ជូនរបស់សហព្រះរាជអាជ្ញាសម្រាប់បញ្ជាក់ពីអំពើ និង អាកប្បកិរិយា") ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥។

[22] ការដាក់ជូនរបស់សហព្រះរាជអាជ្ញាសម្រាប់បញ្ជាក់អំពើ និង អាកប្បកិរិយា កថាខណ្ឌ ២។

[23] ការដាក់ជូនរបស់សហព្រះរាជអាជ្ញាសម្រាប់បញ្ជាក់អំពើ និង អាកប្បកិរិយា កថាខណ្ឌ ៩។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់ ខៀវ សំផន ចំពោះការទទួលយកឯកសារដែលបានស្នើឡើងសម្រាប់សំណុំរឿង ០០២/០២ ឯកសារ E327/3/1 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ កថាខណ្ឌ ៧-១៥។

[25] បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៥ ១៩។

[26] បញ្ជីឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

មានតម្លៃជាភ័ស្តុតាងដែលបានទទួលពីដើមបណ្តឹងរដ្ឋប្បវេណី[27]។ សហមេធាវីនាំមុខតំណាងដើម-បណ្តឹងរដ្ឋប្បវេណី មិនមានបំណងប្រើប្រាស់ឯកសារណាមួយដែលមាននៅក្នុងបញ្ជីឯកសាររបស់ដើមណ្តឹងរដ្ឋប្បវេណីជាភ័ស្តុតាងបង្ហាញពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទឡើយ[28] ប៉ុន្តែនឹងស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើនត្ថិភាពនៃឱកាសក្នុងការសួរដេញដោល កើតមានឡើងនៅពេលក្រោយមកទៀតនោះ[29]។

១២. ក្នុងការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យមានកិច្ចពិភាក្សាដេញដោលអំពីតម្លៃជាភ័ស្តុតាងនៅក្នុងសវនាការលើឯកសារសំខាន់ៗនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបថា វាមិនសមស្របឡើយក្នុងការធ្វើសវនាការវាយតម្លៃភ័ស្តុ-តាងឯកសារទាំងនេះ នៅដំណាក់កាលជំនុំជម្រះដំបូងបែបនេះ[30]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា អង្គជំនុំជម្រះត្រូវវាយតម្លៃថា នឹងផ្តល់តម្លៃជាភ័ស្តុតាងត្រឹមកម្រិតណាទៅឱ្យឯកសារដែលត្រូវបានទទួលយកនេះ នៅពេលក្រោយ[31]។

១៣. ក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់ ខៀវ សំផន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា មេធាវីការពារក្តី ខៀវ សំផន មិនបានផ្តល់នូវការវិភាគដែលមានសំអាងហេតុ ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនអំពីភាពមិនអាចទទួលយកបាននោះឡើយ ប៉ុន្តែគ្រាន់តែបែងចែកឯកសារដែលរងការជំទាស់នោះជាពីរប្រភេទផ្សេងគ្នាប៉ុណ្ណោះ[32]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា ឯកសារមួយចំនួនក្នុងចំណោមឯកសារដែលមេធាវីការពារក្តី ខៀវ សំផន ជំទាស់នោះ ត្រូវបានទទួលយករួចហើយនៅក្នុងសំណុំរឿង ០០២/០១ និង

[27] បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៧។

[28] សេចក្តីជូនដំណឹងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងចម្លើយសាក្សី និង ប្រតិចារឹកនានា ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឯកសារ E327/1 ("សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីអំពីអំពើ និងអាកប្បកិរិយា") ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ៣។

[29] សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីអំពីអំពើ និង អាកប្បកិរិយា កថាខណ្ឌ ៣។

[30] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងឯកសារ E327/3 ឯកសារ E327/3/2 ("ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី") ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ កថាខណ្ឌ ៧។

[31] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៧។

[32] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣។

បានលើកឡើងថា ឯកសារផ្សេងទៀតទាំងអស់ គឺពិតជាពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចដែលបានពិពណ៌នានៅក្នុងបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី[33]។

## ៣.៣ សារណារបស់មេធាវីការពារក្តី នួន ជា

១៤. មេធាវីការពារក្តី នួន ជា ពីដំបូងបានដាក់សេចក្តីជូនដំណឹងមួយដោយបញ្ជាក់ថា មេធាវីការពារក្តីនឹងមិនផ្តល់ជូននូវបញ្ជីឯកសារ និង វត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព អនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈនោះទេ ប៉ុន្តែខ្លួនមានបំណងដាក់វត្ថុតាង និង ឯកសារថ្មីជូនទៅអង្គជំនុំជម្រះនៅពេលក្រោយ តាមរយៈការដាក់សំណើសុំ ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[34]។ ក្រោយមក មេធាវីការពារក្តី នួន ជា បានដាក់បញ្ជីឯកសាររបស់ នួន ជា ក្នុងការឆ្លើយតបទៅនឹងសេចក្តីសម្រេចលើសំណើរួម ដោយបានស្នើសុំដាក់ជូននូវឯកសារចំនួន ២២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្តី នួន ជា អះអាងថា យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមាន ឯកសារដែលមាននៅក្នុងបញ្ជីឯកសាររបស់ នួន ជា គួរតែអាចទទួលយកបាន នៅគ្រប់ពេលវេលាទាំងអស់ រហូតដល់ពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់អង្គជំនុំជម្រះ[35]។ ជាជម្រើសម្យ៉ាងទៀត មេធាវីការពារក្តី នួន ជា លើកឡើងថា ឯកសារនៅក្នុងបញ្ជីឯកសាររបស់ នួន ជា គឺអាចទទួលយកបាន ដោយផ្អែកទៅលើសំអាងហេតុនៃសំណើរួម ឬ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[36]។

១៥. ដោយមិនធ្វើការសម្រេចទៅលើសារណារបស់មេធាវីការពារក្តី នួន ជា លើបញ្ហាអង្គច្បាប់ ដែលចែងអំពីការដាក់បញ្ជីឯកសារ និង វត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាពនោះ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកបញ្ជីឯកសាររបស់ នួន ជា ថាជាបញ្ជីឯកសារមួយក្នុងចំណោមបញ្ជីឯកសារដែលបាន

---

[33] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤, ៥។

[34] សេចក្តីជូនដំណឹងស្តីពីការមិនដាក់បញ្ជីឯកសារ និង វត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ E305/3 ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ២។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានឆ្លើយតបរួចហើយទៅនឹងការដាក់ឯកសារនេះ។ សូមមើល សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និង សេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3) ឯកសារ E307/1 ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[35] បញ្ជីឯកសាររបស់ នួន ជា កថាខណ្ឌ ២-៤។

[36] បញ្ជីឯកសាររបស់ នួន ជា កថាខណ្ឌ ៥-៧។

ធ្វើបច្ចុប្បន្នភាព និង បានដាក់ អនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈ និង សេចក្តីសម្រេចលើសំណើរួម[37]។

១៦. មេធាវីការពារក្តី នួន ជា មិនបានបង្ហាញពីបំណងក្នុងការប្រើប្រាស់សម្ភារៈណាមួយនៅក្នុងបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ខ្លួនថា ជាភស្តុតាងសម្រាប់បញ្ជាក់ពីអំពើ ឬ អាកប្បកិរិយារបស់ជនជាប់ចោទឡើយ។

## ៣.៤ សារណារបស់មេធាវីការពារក្តី ខៀវ សំផន

១៧. បញ្ជីឯកសាររបស់ ខៀវ សំផន. មានចំនួន ១៩៨ ឯកសារ ដែលក្នុងនោះឯកសារមួយចំនួនត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ រួចហើយ។ ពុំមានការកំណត់អត្តសញ្ញាណឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះថាពាក់ព័ន្ធទៅនឹងអំពើ ឬ អាកប្បកិរិយារបស់ជនជាប់ចោទឡើយ។

១៨. មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការសន្មតណាមួយលើភាពអាចទទួលយកបាននៃឯកសារទាំងឡាយដែលត្រូវបានយោងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[38] ។ មេធាវីការពារក្តី ខៀវ សំផន ផ្អែកការជំទាស់របស់ខ្លួនដោយសង្ខេប យោងទៅលើបន្ទុករបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ជាក់ពីពិរុទ្ធរបស់ជនជាប់ចោទ[39]។ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះប្រកាសថា ឯកសារទាំងអស់ដែលបានបង្ហាញក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយដែលសហព្រះរាជអាជ្ញាមិនបានស្នើសុំ គឺមិនពាក់ព័ន្ធ និង មិនអាចទទួលយកបាន[40]។

១៩. មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងឯកសារទាំងអស់នៅក្នុងបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ[41] ដោយអះអាងថា បញ្ជីឯកសារ

---

[37] ដីកាបង្គាប់ស្តីអំពីការជំទាស់ កថាខណ្ឌ ១។

[38] ការជំទាស់ទៅលើភាពអាចទទួលយកបាននៃឯកសារមួយចំនួនដែលត្រូវបានស្នើសុំសម្រាប់ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ និង សំណើសុំឱ្យមានកិច្ចពិភាក្សាដេញដោលមួយពិតប្រាកដពាក់ព័ន្ធនឹងតម្លៃជាភស្តុតាង ឯកសារ E327/3 ("ការជំទាស់របស់ ខៀវ សំផន") ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ កថាខណ្ឌ ៥។

[39] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ៥។

[40] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ២៥។

[41] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៤។

បន្ថែមរបស់សហព្រះរាជអាជ្ញា មិនត្រូវបានដាក់ដោយអនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈ និង សេចក្ដីសម្រេចលើសំណើរួមឡើយ[42]។ មេធាវីការពារក្ដី ខៀវ សំផន លើកឡើងបន្ថែមទៀតថា សហព្រះរាជអាជ្ញាពុំបានដាក់ឯកសារដែលមាននៅក្នុងបញ្ជីឯកសារបន្ថែមរបស់ខ្លួន តាមរយៈសំណើសុំ ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឡើយ ហើយការធ្វើដូចនេះគឺដើម្បីចៀសវាងពីការធ្វើយុត្តិកម្មចំពោះការមិនយកចិត្តទុកដាក់របស់ខ្លួន ដោយគ្រាន់តែស្នើឡើងនូវឯកសារមួយចំនួនដែលមាននៅក្នុងសំណុំរឿងស្រាប់ ឬ នៅក្នុងបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាច្រើនឆ្នាំមកហើយប៉ុណ្ណោះ[43]។

២០. មេធាវីការពារក្ដី ខៀវ សំផន ក៏បានអះអាងថា ការទទួលយកឯកសារទាំងនេះ គឺមានន័យស្មើនឹងការផ្ដល់អត្ថប្រយោជន៍ដោយពុំត្រឹមត្រូវដល់ភាគីសហព្រះរាជអាជ្ញា និង បង្កឱ្យខូចប្រយោជន៍ដល់មេធាវីការពារក្ដី ខៀវ សំផន ហើយហេតុនេះ ស្នើសុំឱ្យអង្គជំនុំជម្រះបដិសេធបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញាជាបន្ទាន់ ឬ ប្រកាសថា ឯកសារទាំងអស់ដែលបានដាក់ជូននៅក្នុងបញ្ជីឯកសារនោះ មិនអាចទទួលយកបាន អនុលោមតាមវិធាន ៨៧(៤) និង ៨៧(៣)(ង) នៃវិធានផ្ទៃក្នុង[44] ។

២១. ផ្សេងពីនេះ មេធាវីការពារក្ដី ខៀវ សំផន ជំទាស់ទៅនឹងឯកសារចំនួន ៨៦ នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និង ឯកសារចំនួន ១៩៣ នៅក្នុងបញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយសំអាងថា ឯកសារទាំងនោះស្ថិតនៅក្រៅវិសាលភាពទាំងស្រុងនៃសំណុំរឿង ០០២/០២[45]។ មេធាវីការពារក្ដី ខៀវ សំផន ក៏ជំទាស់ផងដែរទៅនឹងឯកសារចំនួន ៦០ នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និង ឯកសារចំនួន ១២

---

[42] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៤។

[43] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៥។

[44] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ១៦។

[45] ការជំទាស់របស់ ខៀវ សំផន នៅត្រង់ឧបសម្ព័ន្ធ ក – Exceptions d'irrecevabilité relatives aux documents listés par les co-Procureurs ឯកសារ E327/3.2 ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឧបសម្ព័ន្ធ ខ – Exceptions d'irrecevabilité relatives aux documents listés par les Parties civiles ឯកសារ E327/3.3 ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ (រួមគ្នាហៅថា "ឧបសម្ព័ន្ធភ្ជាប់ទៅនឹងការជំទាស់របស់ ខៀវ សំផន")។

នៅក្នុងបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមេធាវីការពារក្តី ខៀវ សំផន អះអាងថា ជាឯកសារច្រំដែល និង ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង 00២/0២[46]។

២២. ចុងក្រោយ មេធាវីការពារក្តី ខៀវ សំផន ធ្វើសំណើចំនួនពីរដើម្បីសុំការបញ្ជាក់បំភ្លឺ។ ទីមួយ មេធាវីការពារក្តីស្នើសុំការពិភាក្សាដេញដោលស្តីពីតម្លៃជាភ័ស្តុតាងនៃឯកសារនានា[47]។ ដោយកត់សម្គាល់ថា ពុំមានចំណុចណាមួយនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះដែលជូនដំណឹងដល់ភាគីអំពីការរៀបចំសវនាការបង្ហាញឯកសារគន្លឹះនោះ[48] មេធាវីការពារក្តី ខៀវ សំផន ស្នើសុំការបំភ្លឺចំពោះករណីថាតើ ភាគីនឹងត្រូវបានអនុញ្ញាតឱ្យពិភាក្សាពីតម្លៃជាភ័ស្តុតាងនៃឯកសារដែលត្រូវបានដាក់បង្ហាញនៅឯសវនាការដេញដោលលើឯកសារគន្លឹះ ឬ យ៉ាងណា[49]។ ទីពីរ មេធាវីការពារក្តី ខៀវ សំផន ស្នើសុំថា អង្គជំនុំជម្រះគួរចេញសេចក្តីសម្រេចមួយដែលបញ្ជាក់បំភ្លឺបន្ថែមទៀតអំពីវិសាលភាពជាក់លាក់នៃសំណុំរឿង 00២/0២[50]។ ជាពិសេស មេធាវីការពារក្តីស្នើសុំការបញ្ជាក់បំភ្លឺបន្ថែមទៀតពីអង្គជំនុំជម្រះ ដើម្បីខ្លួនអាចសម្រិតសម្រាំងការជ្រើសរើសឯកសារទាំងនេះ។ មេធាវីការពារក្តីលើកឡើងថា បើគ្មានការបញ្ជាក់បំភ្លឺនេះទេ ខ្លួនមិនអាចរៀបចំការជំទាស់ទៅនឹងឯកសារនានាដែលបានស្នើឡើង ដែលអាចនៅក្រៅវិសាលភាពនៃការជំនុំជម្រះ ឬ ជំទាស់ទៅនឹងភាពពាក់ព័ន្ធនៃឯកសារទាំងនោះ ដោយផ្អែកលើវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងបានទេ[51]។ មេធាវីការពារក្តី ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានណាផ្សេងទៀតចំពោះសំណើសុំនេះទេ។

## ៤. ច្បាប់ជាធរមាន

២៣. អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះសំណើសុំឱ្យទទួលយកជាភ័ស្តុតាង នៅពេលអង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងមិនជាប់ពាក់ព័ន្ធ ឬ ជាន់គ្នា មិនអាចរកបានក្នុងរយៈពេលសមស្រប

---

[46] ឧបសម្ព័ន្ធភ្ជាប់ទៅនឹងការជំទាស់របស់ ខៀវ សំផន។

[47] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ២១, ២៣។

[48] ព័ត៌មានអំពី (១) សវនាការនៃការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង 00២/0២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង 00២/0២ ឯកសារ E315/1 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤។

[49] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ២៣។

[50] បញ្ជីឯកសាររបស់ ខៀវ សំផន កថាខណ្ឌ ២៦។

[51] បញ្ជីឯកសាររបស់ ខៀវ សំផន កថាខណ្ឌ ២៥។

ណាមួយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ច្បាប់មិនអនុញ្ញាត ឬ មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬ គ្មានប្រយោជន៍[52]។

២៤. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពីមុនទៅលើឯកសារនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះបានកំណត់គោលការណ៍ទូទៅដែលគ្រប់គ្រងភាពអាចទទួលយកបាននៃឯកសារនានា នៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក[53]។

២៥. បញ្ហាចោទនានាដែលទាក់ទិនទៅនឹងតម្លៃជាភ័ស្តុតាង និងទម្ងន់នៃភ័ស្តុតាងដែលត្រូវផ្តល់ឱ្យឯកសារ ពុំជាប់ពាក់ព័ន្ធទៅនឹងការវាយតម្លៃពីភាពសមស្របរបស់ឯកសារទាំងនោះទៅនឹងលក្ខណៈវិនិច្ឆ័យ ស្របតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងទេ[54]។ អង្គជំនុំជម្រះត្រូវពិចារណាទៅលើតម្លៃ និង ទម្ងន់ នៃភ័ស្តុតាងដែលត្រូវផ្តល់ឱ្យឯកសារក្នុងពេលវាយតម្លៃភ័ស្តុតាងទាំងអស់នៅដំណាក់កាលសរសេរ សាលក្រម[55]។ ការជំទាស់ដែលខ្វះភាពជាក់លាក់សម្រាប់ធ្វើជាមូលដ្ឋាននៃភាពមិនអាចទទួលយក បាននូវឯកសារជាក់លាក់មួយចំនួន ឬ ប្រភេទឯកសារមួយចំនួន ត្រូវបានបដិសេធ[56]។

២៦. ជាទូទៅ កំណត់ហេតុស្តាប់ចម្លើយ ឬ ប្រតិចារឹកមិនអាចទទួលយកបានសម្រាប់គោលបំណង បង្ហាញពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទទេ លើកលែងតែមេធាវីការពារក្តីបានទទួល

---

[52] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[53] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និង ចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ E185 ("សេចក្តីសម្រេចលើកទី១ ស្តីពីក្របខណ្ឌ") ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣០, ៣៣ ដល់ ៣៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និង ឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ E185/1 ("សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើ") ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៨ ដល់ ២២។ សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២០ ដល់ ២១។

[54] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើ កថាខណ្ឌ ១៣។

[55] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើ កថាខណ្ឌ ១៣។

[56] សេចក្តីសម្រេចលើកទី១ ស្តីពីក្របខណ្ឌ កថាខណ្ឌ ២៣។

ឱកាសដេញដោលអ្នកបានផ្តល់ចម្លើយទាំងនេះនៅក្នុងតុលាការ[57]។ អង្គជំនុំជម្រះអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយ ឬ ប្រតិចារិកទាំងនេះជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ប្រសិនបើអ្នកផ្តល់ចម្លើយបានទទួលមរណភាព មិនមានលទ្ធភាពផ្នែកសុខភាពក្នុងការផ្តល់សក្ខីកម្មផ្ទាល់មាត់ ឬ ប្រសិនបើពុំមានលទ្ធភាពក្នុងការស្វែងរកឃើញអ្នកផ្តល់ចម្លើយទាំងនោះ ទោះបីបានខិតខំយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវហើយក៏ដោយ[58]។

## ៥. សេចក្តីសន្និដ្ឋាន

### ៥.១ ការទទួលយកឯកសារ

២៧. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានពិនិត្យទៅលើឯកសារនីមួយៗនៅក្នុងបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ភាគី និង បានដាក់ អនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈ ចំពោះភាពជាប់ពាក់ព័ន្ធ និង ភាពអាចជឿជាក់បាន (រួមទាំងយថាភាពផង)។ អង្គជំនុំជម្រះសាលាដំបូងសំអាងទៅការវិភាគដោយផ្អែកលើវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និង ការជំទាស់ រួមទាំងការធ្វើសេចក្តីសន្និដ្ឋាននានារបស់ភាគី។ អង្គជំនុំជម្រះពិចារណាទៅលើឯកសារដែលត្រឹមត្រូវតាមការបញ្ជាក់ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

២៨. អង្គជំនុំជម្រះបានរៀបចំជាបញ្ជីឯកសារទាំងអស់ ដែលខ្លួននឹងពិចារណាដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធចំនួនប្រាំ៖ ឧបសម្ព័ន្ធ ក រួមមានឯកសារ និង វត្ថុតាងដែលបានដាក់ស្នើដោយសហព្រះរាជអាជ្ញា, ឧបសម្ព័ន្ធ ខ រួមមានឯកសារ និង វត្ថុតាងដែលបានដាក់ស្នើដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ឧបសម្ព័ន្ធ គ រួមមានឯកសារ និង វត្ថុតាងដែលបានដាក់ស្នើដោយមេធាវីការពារក្តី នួន ជា, ឧបសម្ព័ន្ធ ឃ រួមមានឯកសារ និង វត្ថុតាងដែលបានដាក់

[57] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី និង ប្រតិចារិកនៅសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ("សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ និង ប្រតិចារិកសវនាការ") ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧។

ស្នើដោយមេធាវីការពារក្តី ខៀវ សំផន, ឧបសម្ព័ន្ធ ង រួមមានឯកសារនានាដែលមានក្នុងជើងទំព័រនៃកថាខណ្ឌនានាក្នុងដីកាដំណោះស្រាយដែលបង្កើតជាផ្នែកនៃសំណុំរឿង ០០២/០២។

២៩. ឯកសារជាច្រើនដែលអង្គជំនុំជម្រះនឹងពិចារណាដាក់នៅចំពោះមុខខ្លួន ដោយសេចក្តីសម្រេចនេះ នៅមិនអាចរកបានគ្រប់ភាសាដែលប្រើប្រាស់នៅ អ.វ.ត.ក ទេ។ ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃថាតើឯកសារដ៏វែងចំនួនបីជាភាសាអាល្លឺម៉ង់[59] ដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន ជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឬ យ៉ាងណា និង ដើម្បីចៀសវាងការដាក់បន្ទុកដល់អង្គភាពបកប្រែភាសាក្នុងការបកប្រែសំណើសុំដែលមិនមានសារប្រយោជន៍នោះ មេធាវីការពារក្តីត្រូវបានស្នើឱ្យបញ្ជាក់ថាផ្នែកណាខ្លះនៃឯកសារទាំងនេះ ដែលខ្លួនស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ការបញ្ជាក់នេះគួរបញ្ចូល នៅចំណុចដែលសមស្រប រួមមាន សេចក្តីបរិយាយពិស្តារនៃលក្ខណៈ និង ខ្លឹមសារនៃឯកសារទាំងនេះ រួមទាំងការលើកឡើងពីចំណុចដែលជាប់ពាក់ព័ន្ធនានាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[60]។ ការបញ្ជាក់នេះគួរត្រូវបានដាក់ក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីចេញសេចក្តីសម្រេចនេះ។

៣០. អង្គជំនុំជម្រះរម្លឹកដល់ភាគីថា ភាគីណាមួយដែលដាក់ឯកសារនៅពេលសវនាការ នៅតែត្រូវទទួលខុសត្រូវក្នុងការធានាឱ្យឯកសារនោះមានជាភាសាផ្លូវការទាំងបីឱ្យបានទាន់ពេលវេលា[61]។

## ៥.២ ឯកសារនានាដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធ

៣១. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធឯកសារនានាដែលអង្គជំនុំជម្រះសន្និដ្ឋានថា ពុំជាប់ពាក់ព័ន្ធ អានមិនរួច ជាន់គ្នាជាមួយនឹងឯកសារផ្សេងៗទៀតដែលមានក្នុងសំណុំរឿងរួចហើយ ឬ បើមិនដូច្នេះទេ មិនអាចទទួលយកបានអនុលោមតាមលក្ខខណ្ឌនានានៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និង យុត្តិសាស្ត្រដែលបានបង្កើតឡើងដោយអង្គជំនុំជម្រះ។ ក្នុងចំណោមឯកសារទាំងនេះ មានឯកសារ

---

59 *សូមមើល* ឯកសារ E307/5.2.8 ឯកសារ D359/1/1.1.28 និងឯកសារ D359/1/1.1.53។

60 *សូមមើល* ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាពដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ ឯកសារ E305 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ២១១។

61 សេចក្តីសម្រេចលើកទី១ ស្តីពីក្របខណ្ឌ កថាខណ្ឌ ២១។ សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ និង ប្រតិចារឹកសវនាការ ផ្នែកសេចក្តីសម្រេច។ សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មទី ៨ កថាខណ្ឌ ៧.១។

ជាច្រើនដែលអង្គជំនុំជម្រះធ្លាប់បានពិចារណា និង បដិសេធកាលពីមុន។ ឯកសារនានាដែលអង្គ-ជំនុំជម្រះចាត់ទុកថាមិនអាចទទួលយកបានត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធ ច។

### ៥.២.១ *សៀវភៅនិពន្ធដោយ Marcel Lemonde*

៣២. មេធាវីការពារក្តី នួន ជា បានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នូវអត្ថបទសម្រង់ចំនួនបួនពីក្នុងកំណត់ប្រវត្តិដែលនិពន្ធដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel LEMONDE ដែលមានចំណងជើងថា «Un juge face aux Khmers rouges» ដែលជាការរម្លឹកឡើងវិញពីបទពិសោធន៍របស់គាត់នៅ អ.វ.ត.ក[62]។ ទោះជាយ៉ាងណាក្តី មេធាវីការពារក្តី ខៀវ សំផន ធ្លាប់បានធ្វើសំណើមួយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកអត្ថបទសម្រង់ទាំងនេះធ្វើជាភស្តុតាង[63]។ អង្គជំនុំជម្រះបានសម្រេចថា អត្ថបទសម្រង់នីមួយៗក្នុងចំណោមអត្ថបទសម្រង់ទាំងនេះ ដែលពិពណ៌នាពីការយល់ឃើញផ្ទាល់ខ្លួនរបស់ចៅក្រម និង បទពិសោធន៍ផ្សេងៗទៀតដែលមិនទាក់ទិននឹងបញ្ហានានាដែលត្រូវយកមកជំនុំជម្រះ មិនមានប្រយោជន៍ក្នុងការលាតត្រដាងការពិត និង មិនជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទេ[64]។ ហេតុនេះ អង្គជំនុំជម្រះបានបដិសេធមិនទទួលយកសំណើសុំឱ្យទទួលយកឯកសារទាំងនេះមកធ្វើជាភស្តុតាង[65]។ ដោយសារពុំមានអង្គហេតុ ឬ កាលៈទេសៈថ្មីៗនោះ អង្គជំនុំជម្រះពុំពិចារណាសាជាថ្មីទៅលើសេចក្តីសម្រេច

---

[62] បញ្ជីរបស់មេធាវីការពារក្តី នួន ជា នៅត្រង់ឧបសម្ព័ន្ធ ក៖ បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង ០០២/០២ - ក្រុមមេធាវីការពារក្តី នួន ជា ឯកសារ E307/5.2 ("ឧបសម្ព័ន្ធនៃបញ្ជីឯកសាររបស់ នួន ជា") ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៤។

[63] សំណើលើកទី ២ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ឯកសារ E280/2 ("សំណើរបស់ ខៀវ សំផន សុំដាក់សៀវភៅរបស់ Lemonde") ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣។ *សូមមើលផងដែរ* សំណើរបស់ ខៀវ សំផន សុំដាក់សៀវភៅរបស់ Lemonde នៅត្រង់ជើងទំព័រ ៣៩ ស្នើសុំឱ្យទទួលយក ឯកសារ E189/3/1/7.1.1 ឯកសារ E189/3/1/7.1.2 ឯកសារ E189/3/1/7.1.3 និងឯកសារ E189/3/1/7.1.4។ មេធាវីការពារក្តី នួន ជា ក៏ធ្លាប់សំអាងលើសម្រង់អត្ថបទទាំងនេះដែរ នៅក្នុងសំណើមួយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ *សូមមើល* សំណើសុំពិចារណាភស្តុតាងបន្ថែម ឯកសារ E189/3/1/7 ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣។

[64] សេចក្តីសម្រេចលើសំណើសុំលើកទីពីររបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងសុំឱ្យទទួលយកអត្ថបទដកស្រង់ចេញពីសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេត Lemonde (ឯកសារ E280/2) ឯកសារ E280/2/1 ("សេចក្តីសម្រេចលើសំណើសុំដាក់សៀវភៅរបស់ Lemonde") ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧ ដល់ ១៩។

[65] សេចក្តីសម្រេចលើសំណើសុំដាក់សៀវភៅរបស់ Lemonde កថាខណ្ឌ ២០ សេចក្តីសម្រេច។

ពីពេលមុនរបស់ខ្លួនទេ[66]។ ហេតុនេះ សម្រង់អត្ថបទទាំងនេះនឹងមិនដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ។

## ៥.២.២ ***ការលើកឡើងនៅវិទ្យាស្ថាន Aspen***

៣៣. មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន ស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះនូវវីដេអូមួយស្តីពីការលើកឡើងនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ដោយលោកស្រី Silvia CARTWRIGHT នៅឯសន្និសីទមួយនៅវិទ្យាស្ថាន Aspen ក្នុងទីក្រុងវ៉ាស៊ីងតោន ឌីស៊ី សហរដ្ឋអាមេរិក[67] ដែលពេលនោះ លោកស្រីគឺជាចៅក្រមមួយរូបនៃអង្គជំនុំជម្រះនេះ។ មេធាវីការពារក្តី ខៀវ សំផន ក៏បានដាក់ប្រតិចារិកមួយអំពីសម្រង់នានានៃការលើកឡើងទាំងនេះ[68]។ មេធាវីការពារក្តី នួន ជា លើកឡើងថា ការលើកឡើងទាំងនេះជាប់ពាក់ព័ន្ធនឹងបញ្ហានានានៅក្នុងសំណុំរឿង ០០២/០២ រួមទាំងសហករណ៍ និង ការដ្ឋានការងារ ការដាក់បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍ ការរៀបការដោយបង្ខំ ការធ្វើមនុស្សឃាត តួនាទីរបស់ នួន ជា ក្នុងអំឡុងពេលដែលពាក់ព័ន្ធ និង សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ឆាប់រហ័ស[69]។ មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ការលើកឡើងទាំងនេះជាប់ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ និង អង្គហេតុដែលត្រូវបានចោទប្រកាន់ទាក់ទិននឹងការដាក់បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍ និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[70]។

៣៤. មតិយោបល់របស់ចៅក្រម Cartwright នៅវិទ្យាស្ថាន Aspen ទាក់ទិននឹងបទពិសោធន៍របស់គាត់កាលពីពេលដែលគាត់ធ្វើជាចៅក្រមនៅ អ.វ.ត.ក។ ការលើកឡើងរបស់គាត់ផ្តល់ព័ត៌មាន និង

---

[66] សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ៩។

[67] ឧបសម្ព័ន្ធនៃបញ្ជីឯកសាររបស់ នួន ជា នៅត្រង់ទំព័រ ៧។ បញ្ជីឯកសាររបស់ ខៀវ សំផន នៅត្រង់ឧបសម្ព័ន្ធ ៤.ឃ - បញ្ជីឯកសារបន្ថែមដែលពាក់ព័ន្ធផងដែរ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E305/12.5 (“ឧបសម្ព័ន្ធ ៤.ឃ នៃបញ្ជីឯកសាររបស់ ខៀវ សំផន ”) ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ទំព័រ ១៩។

[68] បញ្ជីឯកសាររបស់ ខៀវ សំផន នៅត្រង់ឧបសម្ព័ន្ធ ៣១៖ Transcript video de Madame Cartwright 00’52’58 to 00’59’20: Trying Atrocity Crimes: The Khmer Rouge Trials, Transitional Justice, and the Rule of Law កាលបរិច្ឆេទចេញផ្សាយ៖ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E305/12.32 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។

[69] ឧបសម្ព័ន្ធនៃបញ្ជីឯកសាររបស់ នួន ជា ទំព័រ ៧។

[70] ឧបសម្ព័ន្ធ ៤.ឃ នៃបញ្ជីឯកសាររបស់ ខៀវ សំផន ទំព័រ ១៩។

ចំណាប់អារម្មណ៍ដែលគាត់ទទួលបានពីភារកិច្ចរបស់គាត់ជាចៅក្រមក្នុងសំណុំរឿង ០០២/០១ កិច្ចសន្ទនារបស់គាត់ជាមួយសហការីជាតិដែលមិនបញ្ចេញឈ្មោះ និង យោបល់ផ្ទាល់ខ្លួនគាត់ជាច្រើនទៀត។ ស្រដៀងនឹងកំណត់ប្រវត្តិរបស់ចៅក្រម Lemonde ដែរ ការលើកឡើងរបស់ចៅក្រម Cartwright ដែលពិពណ៌នាអំពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និង បទពិសោធន៍ផ្សេងៗទៀត មិនទាក់ទិននឹងបញ្ហានានាដែលយកមកជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ទេ។ ការលើកឡើងនានានៅវិទ្យាស្ថាន Aspen មិនពាក់ព័ន្ធ និង មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងទេ[71]។

៣៥. លើសពីនេះទៀត មេធាវីការពារក្តី នួន ជា ពុំមានសំអាងហេតុបញ្ជាក់ថា ការលើកឡើងរបស់ចៅក្រម Cartwright នឹងប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ឆាប់រហ័ស ដោយរបៀបណាទេ[72]។ ហេតុនេះ អង្គជំនុំជម្រះពុំអាចដោះស្រាយទឡ្ហីករណ៍នេះបានទេ។ ដោយផ្អែកទៅលើសំអាងហេតុទាំងនេះ វីដេអូ និង ប្រតិចារឹកអំពីការលើកឡើងរបស់ចៅក្រម Cartwright នៅវិទ្យាស្ថាន Aspen នឹងមិនដាក់នៅចំពោះមុខអង្គជំនុំជម្រះទេ។

## ៥.៣ សេចក្តីសន្និដ្ឋានលើការជំទាស់

៣៦. អង្គជំនុំជម្រះសាលាដំបូងរម្លឹកឡើងវិញថា ដីកាបង្គាប់ឱ្យដាក់សម្ភារៈ និង សេចក្តីសម្រេចលើសំណើរួមលើកឡើងយ៉ាងច្បាស់ថា ដំណើរការបច្ចុប្បន្នសម្រាប់ការស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ គឺជាករណីលើកលែងពីដំណើរការធម្មតាសម្រាប់ការដាក់ពាក្យសុំតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារបន្ថែមរបស់ខ្លួន ទៅតាមការណែនាំទាំងនេះ។ នៅក្នុងដីកាសម្រេចលើការជំទាស់ អង្គជំនុំជម្រះបានចាត់ទុកបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញាថា ជាបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាព អនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈ[73]។ ពុំមានភាគីណាមួយជំទាស់ទៅនឹងភាពត្រឹមត្រូវនៃដីកាបង្គាប់ឱ្យដាក់សម្ភារៈទេ[74]។

---

[71] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[72] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើពីមុនរបស់មេធាវីការពារក្តី នួន ជា ដែលប្តឹងជំទាស់ចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូងមិនឱ្យស្តាប់សក្ខីកម្មសំណុំរឿង ០០២/០២ ដោយសំអាងលើការធ្វើកំណត់សម្គាល់ទាំងនេះ។ *សូមមើល* សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ឯកសារ E314/12/1 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១១៦ ដល់ ១២០។

[73] ដីកាសម្រេចលើការជំទាស់ កថាខណ្ឌ ១។

អង្គជំនុំជម្រះក៏បានសម្រេចផងដែរថា ការដាក់លក្ខខណ្ឌឱ្យភាគីត្រូវបង្ហាញថា ឯកសារ និង វត្ថុតាងនៅក្នុងបញ្ជីដែលបានធ្វើបច្ចុប្បន្នភាពរបស់ខ្លួន ថាមិនអាចរកបានមុនពេលសវនាការនឹងមិនស្របតាមគោលបំណងនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងទេ[75]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនពិនិត្យឡើងវិញលើសេចក្តីសម្រេចនានាពីមុនរបស់ខ្លួន ដែលអនុញ្ញាតឱ្យសហព្រះរាជ-អាជ្ញាធ្វើបច្ចុប្បន្នភាពបញ្ជីឯកសារ និង វត្ថុតាងរបស់ខ្លួន ឬ ដែលពិចារណាទៅលើបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា ដែលបានដាក់អនុលោមតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈឡើយ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា សំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលសុំឱ្យបដិសេធដោយពុំចាំបាច់ពិចារណាទៅលើបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា ឬ ក៏តម្រូវឱ្យសហព្រះរាជអាជ្ញាដាក់ពាក្យសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចំពោះបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា គឺគ្មានមូលដ្ឋានសំអាងទេ។

៣៧. ជាងនេះទៀត បើផ្អែកលើការវាយតម្លៃចំពោះឯកសារនានាដែលភាគីបានដាក់ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា គ្មានឯកសារណាមួយដែលមាននៅក្នុងការជំទាស់របស់ ខៀវ សំផន ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ ឬ ជាន់គ្នាទេ។ ហេតុនេះ ឯកសារទាំងនេះនឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

## ៥.៤ សេចក្តីសន្និដ្ឋានទៅលើភស្តុតាងស្តីពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ

៣៨. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អ្នកផ្តល់ចម្លើយម្នាក់ៗដែលមានឈ្មោះនៅក្នុងបញ្ជីរបស់សហ-ព្រះរាជអាជ្ញាសម្រាប់បញ្ជាក់ពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ បានទទួលមរណភាពហើយ[76]។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា កំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញាសម្រាប់បញ្ជាក់ពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ អាចប្រើប្រាស់ជាភស្តុតាងនៃអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទបាននៅក្នុងពេល

---

[74] សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ១១។

[75] សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ១១។

[76] ឧបសម្ព័ន្ធនៃការដាក់ជូនរបស់សហព្រះរាជអាជ្ញាសម្រាប់បញ្ជាក់អំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ។

សវនាការ[77]។ តម្លៃជាភ័ស្តុតាងនៃកំណត់ហេតុទាំងនោះអាចជាកម្មវត្ថុនៃការពិភាក្សាដោយភាគី ហើយអង្គជំនុំជម្រះនឹងពិចារណាពីតម្លៃនៃភ័ស្តុតាងទាំងនេះ នៅពេលក្រោយ។

## ៥.៥ សេចក្តីសន្និដ្ឋានទៅលើការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងដីកាដំណោះស្រាយ និង សំណើសុំការបញ្ជាក់បំភ្លឺ

៣៩. អង្គជំនុំជម្រះសាលាដំបូងទទួលដីកាដំណោះស្រាយពីសហចៅក្រមស៊ើបអង្កេត[78]។ ដីកាដំណោះស្រាយ ជាសេចក្តីសម្រេចដែលមានសំអាងហេតុ[79] បញ្ចប់កិច្ចស៊ើបសួរ ដែលភាគីបានចូលពិនិត្យមើលសំណុំរឿង និង មានឱកាសស្នើសុំបំពេញកិច្ចស៊ើបសួរជាក់លាក់[80]។ អង្គជំនុំជម្រះធ្លាប់បានកត់សម្គាល់ពីមុនថា នៅពេលចប់កិច្ចស៊ើបសួររបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃលើភ័ស្តុតាងទាំងអស់ ជាពិសេស ឯកសារដែលបានដាក់ក្នុងសំណុំរឿង និង ត្រូវបានដកស្រង់ក្នុងដីកាដំណោះស្រាយ និង បានផ្តល់តម្លៃជាភ័ស្តុតាងខ្លះដល់ឯកសារទាំងនោះ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលមានសំអាងហេតុ ដែលបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ[81]។ ហេតុនេះ ទោះបីពុំមានការជំទាស់ថា បន្ទុកក្នុងការបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទត្រូវស្ថិតក្នុងដៃសហព្រះរាជអាជ្ញាក៏ដោយ តែការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតទៅលើឯកសារនានាដែលត្រូវបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ គឺជាមូលដ្ឋានគ្រប់គ្រាន់មួយសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់ឱ្យឯកសារទាំងនោះនូវការសន្មតពីភាពជាប់ពាក់ព័ន្ធ និង ភាពជឿជាក់បាន។

៤០. នៅក្នុងដីកាសម្រេចលើការជំទាស់របស់ខ្លួន អង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគីមានឱកាសក្នុងការជំទាស់ទៅនឹងការសន្មតពីភាពជាប់ពាក់ព័ន្ធ និង ភាពអាចជឿជាក់បាន ចំពោះឯកសារនានាដែល

[77] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ៣២ ដល់ ៣៣។

[78] វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០។

[79] វិធាន ៦៧ នៃវិធានផ្ទៃក្នុង។

[80] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[81] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាងជាឯកសារ កថាខណ្ឌ ៣។ *សូមមើលផងដែរ* វិធាន ៦៧(១), (៣) នៃវិធានផ្ទៃក្នុង។

ត្រូវបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ[82]។ មេធាវីការពារក្តី ខៀវ សំផន បានបដិសេធមិនប្រើប្រាស់ឯកសារនានាដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ តែមិនបានផ្តល់ទឡ្ហីករណ៍ណាមួយដែលមានខ្លឹមសារ ឬ មានសំអាងហេតុ ដែលជំទាស់ពីការសន្មតពីភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន សម្រាប់ឯកសារទាំងនេះទេ[83]។ មេធាវីការពារក្តី ខៀវ សំផន បែរជាផ្អែកទៅលើបន្ទុករបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ សម្រាប់ធ្វើជាសំអាងចំពោះការជំទាស់របស់ខ្លួន ដោយមិនមានការពន្យល់លម្អិតទៅវិញ។ ទឡ្ហីករណ៍នេះពុំមានភាពច្បាស់លាស់ទេ។ ដោយសារ មេធាវីការពារក្តី ខៀវ សំផន មិនបានផ្តល់ទឡ្ហីករណ៍ដែលមានសំអាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការជំទាស់នេះ អង្គជំនុំជម្រះមិនទទួលយកការជំទាស់នេះបានទេ។

៤១. មេធាវីការពារក្តី ខៀវ សំផន ស្នើសុំការបញ្ជាក់បំភ្លឺថាតើខ្លួនអាចបង្ហាញទឡ្ហីករណ៍ស្តីពីតម្លៃជាភស្តុតាងនៃឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ យ៉ាងណា[84]។ អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគី និង ជនជាប់ចោទ ធ្វើការកត់សម្គាល់ទៅលើឯកសារដែលដាក់បង្ហាញដោយភាគីផ្សេងទៀត ក្នុងអំឡុងពេលសវនាការបង្ហាញឯកសារគន្លឹះ ប្រសិនបើពួកគេមានបំណងធ្វើដូច្នេះ[85]។ នៅឯសវនាការបង្ហាញឯកសារគន្លឹះនាពេលថ្មីៗនេះ អង្គជំនុំជម្រះបានបានអនុញ្ញាតឱ្យមេធាវីការពារក្តី ខៀវ សំផន[86] និង មេធាវីការពារក្តី នួន ជា[87] មានយោបល់លើតម្លៃជាភស្តុតាងនៃឯកសារដែលភាគីផ្សេងទៀតបានដាក់។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះនឹងពិចារណាពីតម្លៃជាភស្តុតាង និងទម្ងន់នៃភស្តុតាងនៃឯកសារតែនៅពេលវាយតម្លៃទៅលើភស្តុតាងទាំងមូលនៅក្នុងសវនាការនេះ នៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធីតែ

---

[82] ដីកាសម្រេចលើការជំទាស់ កថាខណ្ឌ ៥។

[83] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158, ឯកសារ E162 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងជាឯកសារ") ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៣, ៨ ដល់ ១៨។ *សូមមើលផងដែរ* វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង។

[84] ការជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ២១, ២៣។

[85] អនុស្សរណៈរបស់អង្គជំនុំជម្រះស្តីពីសវនាការនៃការបង្ហាញឯកសារគន្លឹះ កថាខណ្ឌ ៤។

[86] ប្រតិចារិកសវនាការ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៥១ ដល់ ៥២, ៥៧ ដល់ ៥៨ (ភាសាអង់គ្លេស)។

[87] ប្រតិចារិកសវនាការ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ២៦ ដល់ ៣០ (ភាសាអង់គ្លេស)។ ប្រតិចារិកសវនាការ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ២៣ ដល់ ២៥, ៤៥ (ភាសាអង់គ្លេស)។

01112594



ប៉ុណ្ណោះ[88]។ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីនានាថា ពួកគេនឹងមានឱកាសបង្ហាញនូវទឡ្ហីករណ៍ផ្ទាល់មាត់ស្តីពីតម្លៃជាភស្តុតាងចំពោះឯកសារក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

៤២. ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលសុំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចមួយទៀត ដែលកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ បន្ថែមទៀត[89]។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅលើឯកសារមួយចំនួន ដោយផ្អែកលើមូលដ្ឋានថា ឯកសារទាំងនោះនៅក្រៅវិសាលភាពនៃសំណុំរឿងបច្ចុប្បន្ន[90] ។ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២[91]។ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់សេចក្តីសម្រេចនេះ[92]។ ផ្អែកលើការអនុវត្តដែលបដិសេធការពិចារណាសាជាថ្មីទៅលើសេចក្តីសម្រេចនានារបស់ខ្លួន ដោយពុំមានអង្គហេតុថ្មីៗ ឬ កាលៈទេសៈថ្មីៗនោះ[93] អង្គជំនុំជម្រះនេះបានលើកឡើងថា អង្គជំនុំជម្រះនឹងមិនធ្វើការសម្រេចទូទៅបន្ថែមទៀតលើវិសាលភាពនៃសំណុំរឿង ០០២/០២ ទេ តែផ្ទុយទៅវិញ អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហាចោទជាក់លាក់ ច្បាស់លាស់ ដែលលេចឡើងនៅក្នុងអំឡុងពេលដំណើរការជំនុំជម្រះ[94]។ មេធាវីការពារក្តី ខៀវ សំផន ពុំបានបង្ហាញបញ្ហាបែបនេះដែលតម្រូវឱ្យចេញសេចក្តីសម្រេចមួយទៀតស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឡើយ។

---

[88] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើ កថាខណ្ឌ ១៣។ *សូមមើលផងដែរ* ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ១៩ ដល់ ២០ (ភាសាអង់គ្លេស)។

[89] បញ្ជីឯកសាររបស់ ខៀវ សំផន កថាខណ្ឌ ២៦។

[90] ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសេចក្តីជំទាស់របស់ ខៀវ សំផន។

[91] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤។

[92] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1/1/3 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤កថាខណ្ឌ ៩១។

[93] សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ៤។

[94] អនុស្សរណៈស្តីពីការបំបែកកិច្ចដំណើការនីតិវិធីសំណុំរឿង ០០២ កថាខណ្ឌ ២។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរួម កថាខណ្ឌ ៤។

**តាមសំអាងហេតុនានាដូចដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង ៖**

**ទទួលយក** ដាក់ចំពោះមុខអង្គជំនុំជម្រះនូវ៖

- ឯកសារទាំងអស់ដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ក នៃសេចក្ដីសម្រេចនេះ ដែលរួមមានឯកសារនានាដែលត្រូវបានដាក់តាមរយៈបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និង បញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា។

- ឯកសារទាំងអស់ដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ខ នៃសេចក្ដីសម្រេចនេះ ដែលរួមមានឯកសារនានាដែលត្រូវបានដាក់តាមរយៈបញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី និង បញ្ជីឯកសារបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

- ឯកសារទាំងអស់ដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ គ នៃសេចក្ដីសម្រេចនេះ ដែលរួមមានឯកសារនានាដែលត្រូវបានដាក់តាមរយៈបញ្ជីឯកសាររបស់ នួន ជា។

- ឯកសារទាំងអស់ដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ឃ នៃសេចក្ដីសម្រេចនេះ ដែលរួមមានឯកសារនានាដែលត្រូវបានដាក់តាមរយៈបញ្ជីឯកសាររបស់ ខៀវ សំផន។

**បដិសេធ** សំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលសុំឱ្យប្រកាសមិនទទួលយកឯកសារនានាដែលត្រូវបានដកស្រង់នៅក្នុងដីកាដំណោះស្រាយដែលសហព្រះរាជអាជ្ញាមិនបានស្នើដាក់។

**ទទួល** យកឯកសារទាំងអស់ដែលមានរៀបរាប់នៅក្នុងជើងទំព័រនៃកថាខណ្ឌនានាក្នុងដីកាដំណោះស្រាយដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ង នៃសេចក្ដីសម្រេចនេះ មកដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

**បដិសេធ** ឯកសារទាំងអស់ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ច នៃសេចក្ដីសម្រេចនេះ។

**បដិសេធ** សំណើរបស់មេធាវីការពារក្ដី ខៀវ សំផន សុំឱ្យប្រកាសថា ឯកសារនានាដែលត្រូវបានដាក់នៅក្នុងបញ្ជីឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបាន ឬ ត្រូវដាក់អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

**បដិសេធ** សំណើរបស់របស់មេធាវីការពារក្ដី ខៀវ សំផន សុំឱ្យមានសេចក្ដីសម្រេចថ្មីមួយស្ដីពីវិសាលភាពនៃសំណុំរឿង 00២/0២។

01112596



**ស្នើដល់** មេធាវីការពារក្តី ខៀវ សំផន និង មេធាវីការពារក្តី នួន ជា ដាក់ការបញ្ជាក់អំពីផ្នែកខ្លះៗនៃឯកសារ D359/1/1.28 ឯកសារ D359/1/1.1.53 ឯកសារ E307/5.2.8 ក្នុងរយៈពេល ១៤ ថ្ងៃ ចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ ប្រសិនបើពួកគេមានបំណងចង់ដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

**កត់សម្គាល់** ថា ឯកសារនានាដែលត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ រួចហើយមិនស្ថិតក្នុងសេចក្តីសម្រេចនេះទេ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**